# សេចក្តីប្រកាសព័ត៌មាន

**១២ វិច្ឆិកា ២០០៧**

លោក **អៀង សារី** និង អ្នកស្រី **អៀង ធិរិទ្ធ** ត្រូវឃាត់ខ្លួន និង នាំមកអង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី១២ ខែវិច្ឆិកា ២០០៧ ។ពួកគេបានជួបជាមួយមន្ត្រីនៃអង្គភាពគាំពារការការពារក្តី ដើម្បីជ្រើសរើសសហមេធាវីរបស់ពួកគេ ។

លោក **អៀង សារី** បានជ្រើសរើសលោក **អាង ឧត្តម** ជាសហមេធាវីកម្ពុជា ដើម្បីតំណាងឲ្យគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៧ លោក **អាង ឧត្តម** ប្រកបវិជ្ជាជីវៈជាមេធាវីព្រហ្មទណ្ឌ នៅគំរោងអ្នកការពារក្តីកម្ពុជា(CDP) និងអង្គការជំនួយការផ្នែកច្បាប់នៃកម្ពុជា (LAC) ។ ចាប់ពីឆ្នាំ១៩៩៩ លោកមេធាវី **អាង ឧត្តម** បង្កើតការិយាល័យមេធាវីដោយខ្លួនឯង ហើយចាប់ពីឆ្នាំ ២០០៦ មកដល់បច្ចុប្បន្ននេះ លោកជាប្រធានអង្គភាពច្បាប់នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) ។

លោក **អៀង សារី** បានសំរិតសំរាំងបេក្ខភាពសហមេធាវីបរទេសចំនួនពីររូប ហើយសហមេធាវីបរទេសនឹងចាត់តាំងនៅសប្តាហ៍ក្រោយ ។

អ្នកស្រី **អៀង ធីរិទ្ធ** បានជ្រើសរើសលោក **ផាត់ ពៅស៊ាង** ជាសហមេធាវីកម្ពុជា ដើម្បីតំណាងឲ្យគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ចាប់តាំងពីឆ្នាំ១៩៩៦ លោក **ផាត់ ពៅស៊ាង** ជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។លោក **ផាត់ ពៅស៊ាង** ចាប់ផ្តើមអាជីពជាមេធាវីនៅឆ្នាំ១៩៩៧ ដោយបានការពាររឿងក្តីព្រហ្មទណ្ឌជាច្រើនករណី ហើយធ្វើជាទីប្រឹក្សាច្បាប់ឲ្យគណៈកម្មាធិការនីតិបញ្ញត្តិ និង តុលាការនៃរដ្ឋសភា ។

អ្នកស្រី **អៀង ធិរិទ្ធ** បានជ្រើសរើសកញ្ញា Diana Ellis QC ជាសហមេធាវីបរទេស ។ កញ្ញា Ellis ចូលជាសមាជិកនៃគណៈមេធាវីអង់គ្លេសនិងវែល នៅឆ្នាំ១៩៧៨ និងត្រូវបានចាត់តាំងគោរម្យងារជា **Queen's Counsel** នៅឆ្នាំ ២០០១ ។ កញ្ញា Diana Ellis មានបទពិសោធន៍ច្រើននៅក្នុងការពាររឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ ។ ជាការកត់សំគាល់ កញ្ញា Diana Ellis ធ្លាប់ជាមេធាវីការពារជនជាប់ចោទឈ្មោះ Ferdinand Nahimana នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ាវ៉ាន់ដា ដែលជាសវនាការដំបូងគេបង្អស់ប្រព្រឹត្តទៅនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅលើបទចោទដែលពាក់ព័ន្ធជាមួយតួនាទីនៃសារ ព័ត៌មាននៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

ជនត្រូវចោទទាំងពីរបានអះអាងថា ពួកគេពុំមានមធ្យោបាយបង់ប្រាក់សេវាសហមេធាវីរបស់ពួកគេទេ ។ ហេតុដូច្នេះគំរោងការជំនួយផ្នែកច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ នឹងបង់ប្រាក់កម្រៃសេវ◌ាក្រុមការពារក្តីរបស់ពួកគេ ស្របពេលការអះអាងនេះ កំពុងត្រូវបានវាយតំលៃ ។

